**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី **អាងនាមប្រជារាស្ត្រខ្មែរ**

លេខ : ១១៥ **តុលាការកំពូល**

ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៣

**សាលដីកា** បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី២០ ខែតុលា

លេខ : ២២៦ ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣

១- ឯកឧត្តម **ឃឹម ប៊ុណ្ណ** ប្រធានក្រុមប្រឹក្សាជំនុំជំរះ

២- លោក ប៉ែន សារឿន ចៅក្រមរបាយការណ៍

៣- លោក ជីវ កេង ចៅក្រម

៤- លោក ស៊ិន ឌឹម ចៅក្រម

៥- លោក ប្រាក់ គឹមសាន ចៅក្រម

ក្រឡាបញ្ជី

លោក ឡេង វុធ

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១៥២"ច" ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៦៥ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២របស់សាលាឧទ្ធរណ៍ :

- រវាង ដើមចោទឈ្មោះ វ៉ុន រ៉ាវី (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅសព្វថ្ងៃភូមិខ្ពបវែង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល ។

មានមេធាវីឈ្មោះ ហែម សុជាតិ

- និង ចុងចម្លើយ ព្រះរាជអាជ្ញា អមតុលាការ ខេត្តកណ្តាល ។

- តតិយជនឈ្មោះ ទិត្យ សុងទ្រី (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិករោងចក្របារីសេក ទីលំនៅផ្ទះ លេខ១៣E₀ ផ្លូវលេខ១៤៤ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីលោក ប៊ុន ហ៊ុន

**<u>កម្មវត្ថុបណ្តឹង</u>** : ប្តឹងជំទាស់នឹងការអនុវត្តន៍សាលក្រម ។

បានឃើញបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះ វ៉ុន រ៉ាវី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥២"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១១៥ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០១ របស់ដើមចោទប្តឹងសុំសិទ្ធិគ្រប់គ្រងដីទំហំ៥ម × ៣៨ម ដោយសំអាងហេតុថា ដីទំហំខាងលើខ្លួនបានទិញពីឈ្មោះឃិន សុង នៅឆ្នាំ២០០០ ដោយមានអាជ្ញាធរមូលដ្ឋាន ជាអ្នកដឹងឮ និងទទួលស្គាល់ការលក់ដូរនេះតាមផ្លូវច្បាប់ ។ ក្រោយមកមានសាលក្រមរបស់តុលាការ ដែលមានលោកព្រះរាជអាជ្ញារងបានអនុវត្តមកប៉ះចំលើដី ដែលជាកម្មសិទ្ធិរបស់ខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣៧"ព"ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះវ៉ុន រ៉ាវី ចុះថ្ងៃទី២៣ខែមេសាឆ្នាំ២០០១ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធដោយផ្ទុយនឹងគតិច្បាប់ ។

២-បង្គាប់ឱ្យដើមចោទឈ្មោះ វ៉ុន រ៉ាវី ប្រគល់ដីទំនាស់ទំហំ៥ម × ៣៨ម ដែលស្ថិតនៅក្នុងដី និង ក្បាលដីនៃប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ$C_6$ 0567 ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩២ ឱ្យទៅឈ្មោះ ទិត្យ សុងទ្រី ជាតតិយជន ដែលជាម្ចាស់កម្មសិទ្ធិ និងបង្គាប់ឱ្យដើមចោទឈ្មោះ វ៉ុន រ៉ាវី រុះរើផ្ទះចេញពីដីទំនាស់ឱ្យអស់នៅពេលសាលក្រមចូលជាស្ថាពរ ។

៣-ទុកសិទ្ធិឱ្យដើមចោទប្តឹងទាមទារប្រាក់ថ្លៃទិញដីពីអ្នកលក់នៅតុលាការរដ្ឋប្បវេណី។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ដែលដើមចោទបានបង់ ដោយប្រាក់នេះចំណាយលើកិច្ចស៊ើបសួរពន្ធចុះបញ្ជីក្តី និងពន្ធប្តឹង និងបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រជាប្រាក់ចំនួន២៥ដុល្លា (ម្ភៃប្រាំដុល្លាអាមេរិក) ប្រាក់នេះសំរាប់បង់ចូលថវិការដ្ឋ និងហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ។

៥-សាលក្រមនេះបានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែមេសាឆ្នាំ២០០២ ចំពោះមុខដើមចោទ ,តតិយជន និងមេធាវីផ្ទេរសិទ្ធិ ហើយប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២ ចំពោះមុខដើមចោទ ,តតិយជន បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤២ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះវ៉ុន រ៉ាវី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៣៧"ព"ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២របស់តុលាការ

ខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៥២"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២របស់ឈ្មោះវ៉ុន រ៉ាវី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ៣៧"ព" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២របស់តុលាការខេត្តកណ្តាល ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន៥.០០០រៀល និងលើអាជ្ញាធរ តុលាការចំនួន៥.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះ វ៉ុន រ៉ាវី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥២"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ របស់ឈ្មោះវ៉ុន រ៉ាវី (ជាម្ចាស់បណ្តឹងសាទុក្ខ) ។

បានឃើញសារណាតប ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ របស់លោក ប៊ុន ហុន ជាមេធាវីការពារ និង តំណាងអោយឈ្មោះ ទិត្យ សុងទ្រី (ជាចុងបណ្តឹងសាទុក្ខ) ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖

+ បណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

+ សាលដីការបស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង សំរេច ។

ក្រឡាបញ្ជីអានសារណា របស់ឈ្មោះ វ៉ុន រ៉ាវី នៅពេលសវនាការ ។

របស់ឈ្មោះ ទិត្យ សុងទ្រី បានឆ្លើយនៅពេលសវនាការថា : សូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ប៊ុន ហ៊ុន ជាមេធាវីការពារឱ្យលោកទិត្យ សុងទ្រី នៅពេលសវនាការថា :

អង្គហេតុ : ដីរបស់លោកទិត្យ សុងទ្រី មានទំហំ១៤.០៦១.៦៣៨ម$^{២}$ ដែលស្ថិតនៅភូមិកំពង់សំណាញ់ ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ $C_6$0567 គឺជាដីដែលជាកំណែលតគ្នាពីក្រុមហ៊ុនបារីរំដោះ ដែលមានប័ណ្ណកម្មសិទ្ធិចេញដោយក្រសួងមានសមត្ថកិច្ច រហូតមកដល់ឆ្នាំ១៩៩២ សកម្មភាពរំលោភបំពានកាន់កាប់ដីធ្លីនៅចំណុចនេះ ក៏ចាប់ផ្តើមកើតមានឡើងយ៉ាងអណាធិបតេយ្យ ។

តុលាការបានចេញសាលក្រមឱ្យលោក ទិត្យ សុងទ្រី កាន់កាប់ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយក៏បានចូលជាស្ថាពរទៀត តែពេលអនុវត្តសាលក្រមត្រូវបាន ដើមចោទទាំងប្រាំបីគ្រួសារនេះ បណ្តឹងជំទាស់តែម្តង ។

អង្គច្បាប់ :

សាលក្រមរបស់តុលាការខេត្តកណ្តាលបានសំរេចប្រគល់ដីទំនាស់មកឱ្យលោកទិត្យ សុងទ្រី កាន់កាប់ជាកម្មសិទ្ធិស្របតាមច្បាប់ទាំងអស់ ។

ការប្តឹងនេះ គឺធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍កូនក្តីរបស់ខ្លួនច្រើនណាស់ រហូតដល់សព្វថ្ងៃ ព្រោះថាបណ្តឹងនេះមានកល្លលណៈមិនច្បាស់លាស់បំពានដល់អង្គសេចក្តីទាំងស្រុង ។

តាមលិខិតលេខ$C_6$ 0567ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩២ បានបញ្ជាក់យ៉ាងច្បាស់ថា មានសមត្ថកិច្ចជំនាញទទួលស្គាល់ថា ជាកម្មសិទ្ធិរបស់លោកទិត្យ សុងទ្រី ដោយដំណើរការតាមនីតិវិធីរបស់សូរិយោដីទាំងអស់ ព្រមទាំងកំណត់ហេតុចុះអង្កេតដី និងគំនូសបប្លង់បង្ហាញទីតាំងដីទំនាស់មានលក្ខណៈច្បាស់លាស់តាមច្បាប់ ។

មានលិខិតលេខ០៣៩ ដនសក-ក២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០១ ,លិខិត១៤៥ ដ.ន.ស.ស.គ.ណ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០១ និងលិខិតលេខ១៤ ដ.ន.ស.ក ដីធ្លី ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០២ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សូរិយោដី ខេត្តបញ្ជាក់ថា ដីដែលមានប័ណ្ណសំគាល់សិទ្ធិលេខ $C_6$ 0567 ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩២ មិនមានជាប់ពាក់ព័ន្ធនឹងដីរបស់បុគ្គលណាម្នាក់ទេ គឺម្ចាស់កម្មសិទ្ធិមានរហូតដល់ផ្លូវតែម្តង ។

ដូច្នេះកូនក្តីរបស់ខ្លួនត្រូវបានក្លាយជាម្ចាស់កម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ ។

សំណូមពរ :

- សុំបដិសេធចោលនូវបណ្តឹងរបស់ដើមចោទចោល ។

- សូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សារណារបស់ដើមចោទ និង ចម្លើយរបស់តតិយជនព្រមទាំងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីតតិយជន ។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**<u>តុលាការកំពូល</u>**

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៣១ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣របស់លោកវ៉ុន វ៉ារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងក្នុងសារណាចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ របស់ឈ្មោះ វ៉ុន វ៉ារី ដែលអះអាងថា ខ្លួនបានទិញដីទំហំ៥ម ×៣៨ម កាលពីថ្ងៃ ០៦ ខែតុលា ឆ្នាំ២០០០ពីឈ្មោះ យិន សុង គឺជាដីដែលមិនប៉ះពាល់ដីដែលជាកម្មសិទ្ធិ របស់លោកទិត្យ សុងទ្រី ទេ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា :

ដីទំនាស់ដែលដើមចោទខ្លួនឯងកំពុងរស់នៅកាន់កាប់ គឺជាដីដែលស្ថិតនៅលើក្បាលដី និងចូលក្នុងដីរបស់តតិយជនចុងចំលើយដែលមានប័ណ្ណកម្មសិទ្ធិ លេខC6.0567 ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩២ ដែលប័ណ្ណសំគាល់កម្មសិទ្ធិនេះ អាជ្ញាធរសមត្ថកិច្ចជំនាញ បានទទួលស្គាល់ថា បានកសាងឡើងត្រឹមត្រូវតាមនីតិវិធី និង បានកំណត់ព្រំប្រទល់ច្បាស់លាស់ថា ខាងត្បូងទល់ផ្លូវ ហើយពេលអង្កេតវាស់វែង ក៏ពុំឃើញមានលំនៅដ្ឋានទំនាស់ណាលើដីនោះទេ ។

- យល់ឃើញថា ការដែលដើមចោទប្តឹងតវ៉ាថា ដីខ្លួនពុំមានពាក់ព័ន្ធនៅក្នុងរឿងដីដែលពួកបាតុករលោភយកនោះទេ ទើបខ្លួនទិញនៅថ្ងៃ០៦ ខែតុលា ឆ្នាំ២០០០ ហើយការលក់ទិញនេះ ខ្លួនមានកិច្ចសន្យាត្រឹមត្រូវ មានសាក្សី និង រដ្ឋអំណាចភូមិ-ឃុំទទួលស្គាល់ទៀតផង ។ ការលើកឡើងដូច្នេះ ក៏ជាការពុំត្រឹមត្រូវដែរ ព្រោះថាកន្លងមកអាជ្ញាធរមូលដ្ឋានមានវិធានការណែនាំ និងជូនដំណឹងជាបន្តបន្ទាប់ដូចមានលិខិតចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩២ លិខិតចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៣ លិខិតចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ និង លិខិតចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានហាមឃាត់ដាច់ខាត ដោយមិនអនុញ្ញាតិឱ្យប្រជាជន ឬ កងកំលាំងទៅរំលោភបោះរបង ឬ សាងសង់ ចាប់

យកដីនៅចំណុច០២កន្លែង គឺមួយកន្លែងដីក្នុងភូមិកំពង់សំណាញ់ ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ និង មួយកន្លែងទៀត គឺដីរបស់សាលាវប្បធម៌កងទ័ព ដូច្នេះការដែលប្រជាជនក្ដី កងកំលាំងជីវពលក្ដី ដែល បានចូលកាន់កាប់ និងបន្តលក់ជាបន្តបន្ទាប់ដីត្រង់ចំណុចភូមិកំពង់សំណាញ់ ឃុំកំពង់សំណាញ់ គឺពិតជា បានរំលោភបំពានទៅនឹងសេចក្ដីជូនដំណឹងរបស់អាជ្ញាធរ និងបំពានលើដីកម្មសិទ្ធិឯកជនប្រាកដមែន ។

- យល់ឃើញថា ការដែលតុលាការខេត្តកណ្ដាលសំរេចជំនុំជំរះ និង សំរេចបដិសេធពាក្យ បណ្ដឹងតវ៉ារបស់ដើមចោទ តាមអំណាចសាលក្រមលេខ៣៧"៣" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២ ដោយសំរេចឱ្យដើមចោទប្រគល់ដីឱ្យទៅលោក ទិត្យ សុងទ្រី នោះ គឺជាការត្រឹមត្រូវហើយ ពីព្រោះ ថា :

+តាមលិខិតលេខ០២៨/៩៩ភម ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ការិយាល័យ ភូមិបាលស្រុកតាខ្មៅបានបញ្ជាក់ថា ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីរបស់១៩គ្រួសារ ដែលក្នុងនោះមាន ប័ណ្ណលេខ$C_6$ 0567 ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩២ផង សុទ្ធតែជាប័ណ្ណមានលក្ខណៈត្រឹមត្រូវតាម លក្ខណៈច្បាប់ ។

+តាមលិខិតលេខ១៤៩ដ.ន.ស.ស.កណ ចុះថ្ងៃ១៤ ខែឧសភា ឆ្នាំ២០០១ របស់មន្ទីរ រៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តកណ្ដាលបញ្ជាក់ថា ដីដែលមានកម្មសិទ្ធិលេខ $C_6$ 0567 ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩២ មានព្រំប្រទល់ខាងត្បូងទល់ផ្លូវ មិនមានជាប់ពាក់ព័ន្ធដី របស់បុគ្គលណាទេ ម្ចាស់ប័ណ្ណកម្មសិទ្ធិ ត្រូវមានសិទ្ធិរហូតដល់ផ្លូវតែម្ដង ព្រោះថា ពេលចេញប័ណ្ណនេះ គឺពុំមានផ្ទះ០៥ខ្នង នៅលើដីនោះទេ ។

+តាមលិខិតលេខ៣០ រ.បា ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០១ របស់អភិបាលស្រុក តាខ្មៅបញ្ជាក់ថា ដីរបស់ឈ្មោះទិត្យ សុងទ្រី ពិតជាស្ថិតនៅក្នុងភូមិសាស្ត្រភូមិកំពង់សំណាញ់ ឃុំកំពង់ សំណាញ់ ស្រុកតាខ្មៅខេត្តកណ្ដាល គឺមិនមែនក្នុងភូមិខ្ពបវែង ដូចការអះអាងរបស់ប្រជាជន៨គ្រួសារ នោះឡើយ ។

+តាមលិខិតលេខ១៤ ដ.ន.ស.ក/ដីធ្លី ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០២របស់ក្រសួង រៀបចំដែនដីនគរូបនីយកម្ម និង សំណង់បានឆ្លើយតបទៅប្រជាជន០៨គ្រួសារ វិញថា : គណកម្មការ ដោះស្រាយបាតុភាព បញ្ហាដីធ្លីនៅតាមខេត្តទូទាំងប្រទេស ពុំអាចធ្វើការដោះស្រាយជូនបានទេ ព្រោះ ថា តាមការស្រាវជ្រាវរបស់មន្ត្រីជំនាញ ឃើញថា ប័ណ្ណកម្មសិទ្ធិដីធ្លី លេខ $C_6$ 0567 ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ១៩៩២ បានកសាងឡើងត្រឹមត្រូវតាមនីតិវិធី សុរិយោដីហើយ ។

- យល់ឃើញថា សាលក្រមរបស់តុលាការខេត្តកណ្ដាលលេខ៧៣"រ" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៩ បានចូលជាស្ថាពរ ដោយបានទទួលស្គាល់ប័ណ្ណសំគាល់សិទ្ធិលេខ$C_6$ 0567 ទុកជាត្រឹមត្រូវ

តាមច្បាប់ហើយ ។

- យល់ឃើញថា ការដែលដើមចោទលើកឡើងក្នុងសារណាថា តុលាការខេត្តកណ្ដាល និង សាលាឧទ្ធរណ៍ពុំបានគូរប្លង់ទីតាំងដីទំនាស់ឱ្យបានច្បាស់លាស់ទេ មុននឹងសំរេចសេចក្ដីនោះ តុលាការកំពូលយល់ថា ពុំមែនជាការចាំបាច់ទេ ពីព្រោះក្រោយពីពិនិត្យផ្ទៀងផ្ទាត់លើប័ណ្ណសំគាល់សិទ្ធលេខ $C_6$ 0567 ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩២ ជាមួយកំណត់ហេតុអង្កេតដី ព្រមទាំងគំនូសប្លង់ទីតាំងដីទំនាស់ដែលដើមចោទជូនមកតុលាការជាសំអាង ឃើញថាមានលក្ខណៈគ្រប់គ្រាន់ច្បាស់លាស់ អាចឱ្យតុលាការសំរេចសេចក្ដីបានហើយ ។

- យល់ឃើញថា ដើមចោទបានធ្វើសារណាជូនមកតុលាការរួចហើយ ហើយក៏បានទទួលដីកាកោះរួចដែរ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដោយមេធាវីរបស់លោកបានសុំពន្យាពេលសវនាការតាមពាក្យសុំចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ ថាកូនក្តីលោកទើបតែទទួលដីកាកោះនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៣ ។ តុលាការកំពូលពិនិត្យឃើញថា ពាក្យសុំនេះពុំមានមូលហេតុត្រឹមត្រូវទេ ពីព្រោះកូនក្តីលោកបានទទួលដីកាកោះតាំងពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៣ម្ល៉េះ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៥២"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី ចំពោះមុខលោកទិត្យ សុងទ្រី**

**កំបាំងមុខលោកវ៉ុន រ៉ាវី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្ដឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះវ៉ុន រ៉ាវី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ១៥២"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះទិត្យ សុងទ្រី បានបង់នៅតុលាការកំពូលចំនួន១៩.០០០៛ គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល

- បង្គាប់អោយដើមចោទសងប្រាក់១៩.០០០រៀល ទៅឈ្មោះទិត្យ សុងទ្រីវិញ ។

បង្គាប់អោយដើមចោទ បង់ពន្ធសមាមាត្រតាមការកំនត់របស់តុលាការខេត្តកណ្ដាល ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ ។